# សិទ្ធិរបស់អ្នកក្នុងគម្រោង KNOX-KEENE
# ក្រោមប្រព័ន្ធគ្រប់គ្រងគម្រោងថែទាំសុខភាព DENTAL

បើសិនអ្នកនៅតែមិនយល់ស្រប ជាមួយនឹងការសម្រេចនេះទេ អ្នកអាចៈ

- សូមស្នើសុំ "ការពិនិត្យសុខភាពដោយគ្រូពេទ្យឯករាជ្យ" ហើយអ្នកពិនិត្យមើលពីខាងក្រៅ ដែលមិនពាក់ព័ន្ធនឹងគម្រោងថែទាំសុខភាពធ្មេញរបស់អ្នក នឹងពិនិត្យមើលករណីរបស់អ្នក។

- ស្នើសុំ “សវនាការថ្នាក់រដ្ឋ” ហើយចៅក្រមនឹងពិនិត្យមើលករណីរបស់អ្នក។

អ្នកអាចស្នើសុំ ការពិនិត្យពិច័យដោយពេទ្យឯករាជ្យ និង រដ្ឋសវនាការ ទាំងពីរមុខនៅពេលព្រមគ្នាបាន។ អ្នកក៏អាចស្នើសុំការមួយ មុនការមួយទៀតដែរ ក្រែងលោបើវានឹងដោះស្រាយបញ្ហារបស់អ្នក បានមុន។ ឧទាហរណ៍ បើសិនអ្នកស្នើសុំការពិនិត្យពិច័យ ដោយពេទ្យឯករាជ្យ ជាមុន ប៉ុន្តែមិនយល់ស្រប ជាមួយនឹងការសម្រេចទេ អ្នកនៅតែអាចស្នើសុំ រដ្ឋសវនាការ នៅពេលក្រោយ។ ប៉ុន្តែ ប្រសិនបើអ្នកស្នើសុំសវនាការថ្នាក់រដ្ឋជាមុន ហើយការស្តាប់បណ្តឹងនោះបានធ្វើឡើងរួចហើយ នោះអ្នកមិនអាចស្នើសុំការពិនិត្យសុខភាពដោយគ្រូពេទ្យឯករាជ្យបានទេ។ នៅក្នុងករណីនេះ រដ្ឋសវនាការ មានការសម្រេចជាចុងក្រោយ។

អ្នកមិនចាំបាច់បង់ប្រាក់សម្រាប់ការពិនិត្យសុខភាពដោយគ្រូពេទ្យឯករាជ្យ ឬសវនាការថ្នាក់រដ្ឋទេ។

---

<u>ការពិនិត្យសុខភាពដោយគ្រូពេទ្យឯករាជ្យ (IMR)</u>

បើសិនអ្នកចង់បានការពិនិត្យសុខភាពដោយគ្រូពេទ្យឯករាជ្យ អ្នកត្រូវតែស្នើសុំក្នុងពេល <u>180 ថ្ងៃ</u> ចាប់តាំងពីកាលបរិច្ឆេទមើលលិខិតជូនដំណឹងដំណោះស្រាយបណ្តឹងឧទ្ធរណ៍។ កថាខណ្ឌខាងក្រោមផ្តល់ព័ត៌មានជូនអ្នក ស្តីពីរបៀបស្នើសុំការពិនិត្យសុខភាពដោយគ្រូពេទ្យឯករាជ្យ។[1] សូមកត់សម្គាល់ថា ពាក្យ “បណ្តឹងសាទុក្ខ” គឺនិយាយអំពីទាំង “បណ្តឹងតវ៉ា” និង “បណ្តឹងឧទ្ធរណ៍”។

“California Department of Managed Health Care មានភារៈកិច្ចសម្រាប់ការដាក់បញ្ញត្តិ ដល់គម្រោងសេវាថែទាំសុខភាព។ ប្រសិនបើអ្នកមានបណ្តឹងសាទុក្ខប្រឆាំងនឹងគម្រោងថែទាំសុខភាពធ្មេញរបស់អ្នក ដំបូងអ្នកគួរតែទូរសព្ទ ទៅគម្រោងសុខភាពធ្មេញរបស់អ្នក តាមរយៈលេខ **1-844-233-4522, TTY: 1-800-466-7566** និងប្រើដំណើរការបណ្តឹងសាទុក្ខគម្រោងថែទាំសុខភាពធ្មេញរបស់អ្នក មុននឹងទាក់ទងក្រសួង។ ការប្រើវិធីធ្វើសាទុក្ខនេះ មិនហាមឃាត់សិទ្ធិស្របច្បាប់អ្វីមួយ ដែលអាចយកមកប្រើ ឬដំណោះស្រាយអ្វីៗ ដែលអាចមានសម្រាប់អ្នកឡើយ។

[1] ច្បាប់ស្តីពីសុខភាព និងសុវត្ថិភាព (HSC) ផ្នែក 1368.02(b)។ HSC គឺអាចរកឃើញបាន នៅៈ https://leginfo.legislature.ca.gov/faces/codesTOCSelected.xhtml

សម្រាប់គម្រោង Knox-Keene Plans (NAR)

បើសិនអ្នកត្រូវការជំនួយក្នុងការដោះស្រាយបណ្តឹងសាទុក្ខ ដែលទាក់ទងនឹងភាពអាសន្ន ឬបណ្តឹងសាទុក្ខមួយដែលគម្រោងសុខភាពរបស់អ្នក មិនទាន់បានដោះស្រាយឱ្យបានពេញចិត្តនៅឡើយ ឬបណ្តឹងសាទុក្ខដែលនៅតែមិនទាន់ដោះស្រាយរួចលើសពីចំនួន 30 ថ្ងៃ អ្នកអាចទូរសព្ទទៅក្រសួងដើម្បីទទួលបានជំនួយ។ អ្នកក៏អាចនឹងមានសិទ្ធិទទួលការពិនិត្យពិច័យដោយពេទ្យឯករាជ្យ (Independent Medical Review, IMR) ដែរ។ ប្រសិនបើអ្នកមានសិទ្ធិទទួលបាន IMR ដំណើរការនេះនឹងផ្តល់ការពិនិត្យដោយយុត្តិធលើសេចក្តីសម្រេចចិត្តផ្នែកវេជ្ជសាស្ត្រដែលធ្វើឡើងដោយគម្រោងថែទាំសុខភាព ដែលទាក់ទងនឹងភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រនៃសេវា ឬការព្យាបាលដែលបានស្នើសុំឡើង សេចក្តីសម្រេចចិត្តលើការធានារ៉ាប់រងសម្រាប់ការព្យាបាលដែលមានលក្ខណៈពិសោធន៍ ឬស្រាវជ្រាវ និងវិវាទទូទាត់ប្រាក់សម្រាប់សេវាវេជ្ជសាស្ត្របន្ទាន់ ឬសង្គ្រោះបន្ទាន់។ ក្រសួងក៏មានលេខទូរសព្ទឥតចេញថ្លៃ **(1-888-466-2219)** និងខ្សែទូរសព្ទ TDD **(1-877-688-9891)** សម្រាប់អ្នកមានបញ្ហាការស្តាប់ និងការនិយាយផងដែរ។ គេហទំព័ររបស់ក្រសួង (**www.dmhc.ca.gov**)មានទម្រង់បំពេញបណ្តឹង ទម្រង់បំពេញពាក្យសុំ IMR និងសេចក្តីណែនាំតាមអនឡាញ"។

---

## សវនាការថ្នាក់រដ្ឋ

ប្រសិនបើអ្នកចង់បានសវនាការថ្នាក់រដ្ឋ អ្នកត្រូវតែស្នើសុំមិនឱ្យហួសពី 120 ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងអំពីដំណោះស្រាយបណ្តឹងឧទ្ធរណ៍នេះ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគម្រោងថែទាំសុខភាពធ្មេញរបស់អ្នកបន្តផ្តល់ជូនអ្នកនូវសេវាដែលមានជម្លោះ (ការឧបត្ថម្ភបានបង់កំពុងរង់ចាំ) ក្នុងអំឡុងពេលដំណើរការបណ្តឹងឧទ្ធរណ៍របស់គម្រោងថែទាំសុខភាពធ្មេញ ហើយអ្នកចង់ឱ្យសេវានោះបន្តរហូតដល់មានការសម្រេចលើសវនាការថ្នាក់រដ្ឋ អ្នកត្រូវតែស្នើសុំសវនាការថ្នាក់រដ្ឋក្នុងរយៈពេល 10 ថ្ងៃ គិតចាប់ពីលិខិតជូនដំណឹងអំពីដំណោះស្រាយបណ្តឹងឧទ្ធរណ៍នេះ។ ទោះបើគម្រោងថែទាំសុខភាពធ្មេញរបស់អ្នកត្រូវតែផ្តល់ជូនជំនួយបានបង់មិនទាន់ដាច់ស្រេចដល់អ្នក នៅពេលអ្នកស្នើសុំសវនាការថ្នាក់រដ្ឋតាមរបៀបនេះក៏ដោយ អ្នកគួរតែប្រាប់ដំណឹងគម្រោងថែទាំសុខភាពធ្មេញរបស់អ្នកថា អ្នកចង់ទទួលជំនួយបានបង់មិនទាន់ដាច់ស្រេច រហូតទាល់តែសវនាការថ្នាក់រដ្ឋរបស់អ្នកបានសម្រេច។ អ្នកគួរតែទាក់ទង Health Net Dental ចន្លោះពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ តាមរយៈលេខទូរសព្ទ 1-844-233-4522។ ប្រសិនបើអ្នកមិនអាចស្តាប់បាន ឬនិយាយមិនបានល្អ សូមហៅទូរសព្ទទៅកាន់ TTY/TDD៖ 1-800-466-7566។

អ្នកអាចស្នើសុំ រដ្ឋសវនាការ ក្នុងរបៀបខាងក្រោម៖

- អនឡាញតាមរយៈ: www.cdss.ca.gov

- តាមទូរសព្ទ៖ ហៅ 1-800-743-8525។ លេខនេះអាចជារវល់ណាស់។ អ្នកអាចនឹងទទួលសារ ឲ្យទូរសព្ទមកវិញ នៅពេលក្រោយទៀត។ បើសិនអ្នកមិនអាចនិយាយបាន ឬស្តាប់មិនឮល្អ សូមហៅ TTY/TDD 1-800-952-8349។

- ជាលាយល័ក្ខណ៍អក្សរ៖ បំពេញទំរង់បំពេញ រដ្ឋសវនាការ ឬផ្ញើសំបុត្រ។ ផ្ញើវាតាមប្រៃសណីយ៍ ឬតាមទូរសារ ទៅ៖

  ប្រៃសណីយ៍៖ California Department of Social<br>State Hearings Division<br>P.O. Box 944243, Mail Station 9-17-37<br>Sacramento, CA 94244-2430

  ទូរសារ៖ (916) 309-3487 ឬលេខឥតចេញថ្លៃ 1-833-281-0903

  ក្រដាសបំពេញរដ្ឋសវនាការ គឺបានភ្ជាប់មកជាមួយសំបុត្រនេះ។ ត្រូវបញ្ចូលឈ្មោះ, អាសយដ្ឋាន, លេខទូរស័ព្ទ, និងលេខសូស្យាល់សិគ្យូរិទីរបស់អ្នក, ព្រមទាំងមូលហេតុដែលអ្នកចង់បានរដ្ឋសវនាការ។ បើសិនជនណាម្នាក់ដែលជួយអ្នកស្នើសុំរដ្ឋសវនាការ ក៏ត្រូវបន្ថែមនូវឈ្មោះ, អាសយដ្ឋាន, និងលេខទូរសព្ទរបស់គេ ទៅនឹងទំរង់បំពេញ ឬសំបុត្រដែរ។ បើសិនអ្នកត្រូវការអ្នកបកប្រែ ត្រូវប្រាប់ផ្នែករដ្ឋសវនាការ នូវភាសាដែលអ្នកនិយាយ។ អ្នកនឹងមិនត្រូវបង់ ប្រាក់សម្រាប់អ្នកបកប្រែទេ។ ផ្នែករដ្ឋសវនាការ នឹងរកអ្នកបកប្រែសម្រាប់អ្នក។ បើសិនអ្នកមានភាពពិការ ផ្នែករដ្ឋសវនាការ អាចរកការសំរបសំរួលពិសេសឲ្យអ្នកឥតគិតថ្លៃ ដើម្បីជួយអ្នកចូលរួមក្នុងការធ្វើសវនាការ។ សូមបញ្ចូលព័ត៌មាន អំពីភាពពិការរបស់អ្នក និងការសំរបសំរួល ដែលអ្នកត្រូវការ។

បន្ទាប់ពីអ្នកស្នើសុំ រដ្ឋសវនាការមក វាអាចនឹងប្រើពេលដល់ទៅ 90 ថ្ងៃ ដើម្បីសម្រេចទៅលើករណីរបស់អ្នក និងផ្ញើចំឡើយឲ្យអ្នក។ ប្រសិនបើអ្នកគិតថា ការរង់ចាំរយៈពេលយូរនោះនឹងប៉ះពាល់ដល់សុខភាព ឬមុខងារធ្មេញរបស់អ្នក អ្នកប្រហែលជាអាចទទួលបានចម្លើយក្នុងរយៈពេល 3 ថ្ងៃ។ សូមស្នើសុំឱ្យពេទ្យធ្មេញ ឬគម្រោងថែទាំសុខភាពធ្មេញរបស់អ្នកសរសេរលិខិតមួយជូនអ្នក។ លិខិតនោះត្រូវតែពន្យល់លម្អិតអំពីរបៀបដែលការរង់ចាំរហូតដល់ 90 ថ្ងៃ ដើម្បីឱ្យករណីរបស់អ្នកបានសម្រេច នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព ឬមុខងារធ្មេញរបស់អ្នក។ ជាបន្ទាប់មក ក៏ធ្វើឲ្យប្រាកដថាអ្នកស្នើសុំ សវនាការដោយពន្លឿន និងផ្តល់សំបុត្រ មកជាមួយសំណើរបស់អ្នក សម្រាប់សវនាការ។

អ្នកអាចនឹងនិយាយ នៅឯរដ្ឋសវនាការ ដោយខ្លួនឯង។ អ្នកអាចមានសាច់ញាតិ មិត្តភក្តិ អ្នកតស៊ូមតិ ពេទ្យធ្មេញ ឬមេធាវី និយាយជំនួសអ្នក។ ប្រសិនបើអ្នកចង់ឱ្យអ្នកផ្សេងនិយាយជំនួសអ្នក នោះអ្នកត្រូវតែប្រាប់ការិយាល័យសវនាការថ្នាក់រដ្ឋថា អ្នកនោះត្រូវបានអនុញ្ញាតឱ្យនិយាយជំនួសអ្នក។ មនុស្សនេះគឺហៅថា អ្នកតំណាងបានអនុញ្ញាត។

សម្រាប់គម្រោង Knox-Keene Plans (NAR)

## <u>ជំនួយផ្នែកច្បាប់</u>

អ្នកអាចនឹងទទួល ជំនួយខាងច្បាប់ឥតគិតថ្លៃ។ សូមហៅទូរសព្ទទៅកាន់ខ្សែទូរសព្ទផ្តល់ជំនួយរបស់មជ្ឈមណ្ឌលសិទ្ធិថែទាំសុខភាព (Center for Health Care Rights) តាមរយៈលេខ 1-800-824-0780។ អ្នកក៏អាចហៅសង្គមជំនួយខាងច្បាប់ តាមមូលដ្ឋាន ក្នុងខោនធីរបស់អ្នក លេខ 1-888-804-3536 ដែរ។